ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំព្រហ្មទណ្ឌ

លេខ:១៩៨/២០-០២-២០១៣

សាលដីកា

លេខ:៥៦ ក្រIVត/២២-០៨-២០១៣

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ១៩៨ ចុះថ្ងៃទី២០-០២-២០១៣រវាង៖

-ជនជាប់ចោទឈ្មោះ [redacted] ណា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិបុសខ្នុរ ឃុំសំពណ៌ា ស្រុកចំការលើ ខេត្តកំពង់ចាម និងទីលំនៅសព្វថ្ងៃមិនពិតប្រាកដ ក្នុងរាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ។ ឃុំខ្លួនចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១២ ( ដើមបណ្តឹងឧទ្ធរណ៍)

មេធាវី [redacted] អូន

ត្រូវចោទពីបទៈឃាតកម្ម និង លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តិនៅចំណុចផ្ទះសំណាក់ពន្លឺច័ន្ទ ផ្លូវលំ ភូមិសន្សំកុសល សង្កាត់បឹងទំពុន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ខែសីហា ឆ្នាំ២០១២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១៩៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គីមអេង ភេទស្រី អាយុ៨៧ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះជួលភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ឯរឿងហេតុមានដូចតទៅ៖

កាលពីយប់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១២វេលាម៉ោងប្រហែល២១និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] ហាលីម [redacted] ហាហៀង បានជិះម៉ូតូម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ១AH-៣៣៩៨ ឧប

ជនល្មើសឈ្មោះ[redacted] ណា ចូលផ្ទះសំណាក់ពន្លឺច័ន្ទ ផ្លូវលំ ភូមិចំរើនផល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ពេលចូលមកដល់ក្នុងបន្ទប់លេខA២០០ ជនរងគ្រោះបានលេងប្រដាប់ភេទឈ្មោះ[redacted]ណា ធ្វើឲ្យគាត់ខឹងក៏បានយកកូនកាំបិតពីក្នុងហោប៉ៅខោចាក់ត្រូវចំពោះជនរងគ្រោះ រួចក៏មានការប្រវាយប្រតប់គ្នា ហើយឈ្មោះ[redacted] ណា បានចាក់ជនរងគ្រោះបន្ថែមជាច្រើនកាំបិតទៀតបណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមនៅហ្នឹងកន្លែងកើតហេតុ។បន្ទាប់មកជនល្មើសឈ្មោះ[redacted]ណា បានប្រមូលយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះរួមមានទូរស័ព្ទដៃ ប្រាក់មិនដឹងចំនួននិងសំបុត្រផ្ញើរម៉ូតូហើយបានចុះទៅយកម៉ូតូជិះគេចខ្លួនតែត្រូវសន្តិសុខយាមផ្ទះសំណាក់ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចរួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៥០ក្រ"ថ" ចុះថ្ងៃទី២៨-១២-២០១២របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ[redacted] ណា ភេទប្រុស អាយុ១៩ឆ្នាំ(មានសារពើភ័ណ្ឌខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល១៥ (ដប់ប្រាំ) ឆ្នាំ ពីបទៈឃាតកម្ម និង លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅផ្ទះសំណាក់ពន្លឺច័ន្ទ ភូមិសន្សំកុសលទី១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ខែសីហា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា១៩៩,៣៥៣,៣៥៧,១៣៧ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ[redacted]ណា សងសំណងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងឈ្មោះ[redacted]គីមអេង ជាទឹកប្រាក់ចំនួន៤០.០០០.០០០រ(សែសិប)លានរៀល ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

៣-វត្ថុតាងយករួមមាន

ក-កូនកាំបិតដងលឿងចំនួន០១ ត្រូវរឹបអូសបំផ្លាញចោល ។

ខ-ទូរស័ព្ទដៃ០១ គ្រឿង ម៉ាកស្វូនីអេរិកសាន់W៣៩៥, ប្រាក់ខ្មែរចំនួន១២.០០០រៀល+ប្រាក់ដុល្លាចំនួន០១$ និង ប័ណ្ណផ្ញើរកង់-ម៉ូតូលេខ ០៨៩១៧០ ចំនួន០១សន្លឹក ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញសេចក្តីថ្លែងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០១-២០១៣ របស់ជនជាប់ចោទឈ្មោះ[redacted] ណា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៥០(ក្រ២ថ) ចុះថ្ងៃទី២៨-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញរបាយការណ៍ចុះថ្ងៃទី១០-៦-២០១៣ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ[redacted]ណា បានឆ្លើយបញ្ជាក់ថា ខ្លួនទទួលស្គាល់បានចាក់គេមែន តែមិនបានលួចយករបស់គេទេ ។ ខ្លួនគ្មានចេតនាសម្លាប់ទេ ដោយសារគេលូកលាន់ទើបខ្លួនខឹង ហើយចម្លើយនៅសមត្ថកិច្ចខ្លួនមិនទទួលស្គាល់ទេ។ កាំបិតខ្លួនចិតផ្លែឈើហូប ដើរហូបបណ្តើរៗរួចដាក់នៅជិតខ្លួន។ ខ្លួនមិនស្គាល់ជនរងគ្រោះទេ គឺជនរងគ្រោះបានបបួលខ្លួនដើរលេងកោះពេជ្រនាំញ៉ាំបង្អែមហើយនាំចូលផ្ទះសំណាក់ ហើយនៅក្រោយពេលចាក់គេរួចខ្លួនមិនបានយកម៉ូតូចេញទេ ។ សំណូមពរសុំលើកលែងចោទពីបទប្លន់។

តំណាងបហារយ្យការផ្តល់សេចក្តីសន្និដ្ឋាន

ឯកភាពលើរង្គហេតុ ចម្លើយជនជាប់ចោទគ្មានភស្តុតាង តែសុំក្រុមប្រឹក្សាពិចារណាលើទ្រព្យសម្បត្តិជនរងគ្រោះតើគាត់បានយកឬមិនបានយក និងសុំសំរេចតាមច្បាប់។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ០២-០១-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ណា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១៥០ក្រ"ច"ចុះថ្ងៃទី២៨-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានសារភាពថា បានបាក់សម្លាប់ជនរងគ្រោះ ដោយសារជនរងគ្រោះបានចាប់លេងប្រដាប់ភេទខ្លួន ខ្លួនប្រាប់ឲ្យឈប់លេងតែមិនស្ដាប់ ។ បន្ទាប់ពីចាក់រួចខ្លួនបានចាកចេញពីផ្ទះសំណាក់ ប៉ុន្តែត្រូវសន្តិសុខរោគខ្លួន ។ខ្លួនមិនបានយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះ តែបានយកសំបុត្រម៉ូតូចុះមកយកម៉ូតូ ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ១៥០ក្រ"ច" ចុះថ្ងៃទី២៨-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមទុកជាបានការ ។

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០១-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ណាទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥០ក្រ"ច" ចុះថ្ងៃទី២៨-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទខាងលើ តាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះ ចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] ណា និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ក្រឡាបញ្ជី
ហត្ថលេខា: [redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា: [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជំរះ
ហត្ថលេខា: [redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 23 ខែមីនា ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]